*Kampuchean Action for Primary Education*

# អង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា

ឯកសារយោង

# ទំនាក់ទំនងជាមួយឪពុកម្តាយ

( សេចក្តីព្រាង )

កំពង់ចាម , ខែ ៦ ២០០៣

ឧបត្ថម្ភគាំទ្រដោយអង្គការ យូនីសេហ្វ / ស៊ីដា

# ទំនាក់ទំនងជាមួយឪពុកម្តាយ

## I. សេចក្តីផ្តើម :

កម្មវិធីសាលាកុមារមេត្រី គួរតែពង្រឹងទំនាក់ទំនងគ្រប់មាតាបិតាសិស្ស ( សហគមន៍ ) ជាមួយគ្រូ ( សាលារៀន ) ។ មាតាបិតាមានតួនាទីសំខាន់ក្នុងការអប់រំកូនគេ ទោះបីជាកម្រិតវប្បធម៌របស់គេខ្ពស់ ឬ ទាប ក៏ដោយ ។ ក្នុងពេលកន្លងមកនៅប្រទេសកម្ពុជា សកម្មភាពរបស់មាតាបិតាសិស្ស និង សហគមន៍ ក្នុងការអប់រំច្រើនតែជាការងាររៃអង្គាសលុយ ។ ទោះបីជាយ៉ាងណាក៏ដោយអន្តរាគមន៍ ដូចជា កម្មវិធីអាហារពេលព្រឹក , អាហារូបករណ៍ និង បំណិនជីវិត បានអោយសហគមន៍ធ្វើការងារសំខាន់ ៗ ក្រៅពីការងាររៃអង្គាសលុយ ។ ឯកសារនេះ ជូនយោបល់ថែមទៀត ដើម្បីជួយពង្រឹងទំនាក់ទំនងរបស់សាលារៀនជាមួយមាតាបិតាសិស្ស ។

## II. គោលបំណង :

កុមារទទួលការលើកទឹកចិត្ត ក្នុងការរៀន និង ការសិក្សា ដោយសារមានទំនាក់ទំនងយ៉ាងទៀងទាត់រវាងសាលារៀន និង មាតាបិតា ។

## III. រយៈពេល :

តម្រង់ទិសរយៈពេល ២ ម៉ោង ពេលប្រជុំបច្ចេកទេសថ្ងៃព្រហស្បតិ៍ ដោយមានការចូលរួមពីគ្រូ និង សហគមន៍ ។

## IV. ធនធាន និង សម្ភារ :

- ក្រដាសផ្ទាំងធំ
- ហ្វឺត
- ស្កុត ។

## V. លំនាំបង្រៀន :

### 1. ការពង្រឹងទំនាក់ទំនងរវាងមាតាបិតា និង គ្រូ :

- អ្នកសម្របសម្រួលពន្យល់ដល់គ្រូថា សាលាចង់រៀបចំសកម្មភាពដើម្បីពង្រឹងទំនាក់ទំនងរវាងគ្រូ និង មាតាបិតា ។
- អ្នកសម្របសម្រួល អោយសមាជិកសហគមន៍ និង គ្រូបង្រៀនពិចារណាលើសំណួរខាងក្រោមនេះ ÷

ក/ តើទំនាក់ទំនងល្អរវាងមាតាបិតា និង គ្រូ មានសារៈសំខាន់អ្វីខ្លះ ?

ចូរពិចារណាលើគំនិតខាងក្រោមនេះ ÷

- ឥទ្ធិពលលើការរៀនសូត្ររបស់សិស្ស
- បង្កើនភាពស្និទ្ធស្នាលរវាងមាតាបិតា និង គ្រូ
- មាតាបិតាយល់កាន់តែច្បាស់អំពីសកម្មភាពក្នុងសាលារៀន
- គ្រូយល់កាន់តែច្បាស់អំពីស្ថានភាពរស់នៅរបស់មាតាបិតាសិស្ស ។

ខ/ តើយើងធ្វើយ៉ាងដូចម្តេច ដើម្បីពង្រឹងទំនាក់ទំនងរវាងមាតាបិតា និង គ្រូ ?

ចូរពិចារណាលើគំនិតខាងក្រោមនេះ ÷

- ការរៀបចំថ្ងៃពិសេសអញ្ជើញមាតាបិតាមកសាលារៀន
- ការរៀបចំទស្សនកិច្ចដល់ថ្នាក់រៀនសម្រាប់ឪពុកម្តាយ
- ការប្រើប្រាស់សៀវភៅទំនាក់ទំនង
- ការប្រើប្រាស់សៀវភៅតាមដាន ។

❖ អ្នកសម្របសម្រួល គួរតែពន្យល់សកម្មភាពនីមួយ ៗ ខាងលើនេះ ÷

<u>ការរៀបចំថ្ងៃពិសេសសម្រាប់មាតាបិតាក្នុងសាលារៀន</u> : សាលារៀនអាចរៀបចំថ្ងៃពិសេសសម្រាប់មាតាបិតាសិស្សក្នុងសាលារៀន ១ ឆ្នាំ ២ ដង ។ មាតាបិតា អាចទស្សនកិច្ចបណ្ណាល័យ , បន្ទប់ធនធានសម្ភារ , សកម្មភាពរបស់សិស្ស និង ការចំណាយថវិការបស់សាលាក្នុងឆ្នាំសិក្សា ។ ម្យ៉ាងទៀត សិស្សអាចរៀបចំសកម្មភាពសិល្បះ ។ សាលារៀន អាចផ្តល់ថវិកាខ្លះសម្រាប់ភេសជ្ជៈ ។ សិស្សអាចគូររូបភាពលើលិខិតអញ្ជើញមាតាបិតាសិស្សសម្រាប់ថ្ងៃពិសេសនេះ ។

<u>ការរៀបចំទស្សនកិច្ចថ្នាក់រៀនរបស់មាតាបិតា</u> : នៅដើមឆ្នាំសិក្សា និង ដើមឆមាសទី ២ គ្រូអាចរៀបចំទស្សនកិច្ចថ្នាក់រៀនសម្រាប់មាតាបិតាសិស្ស ។ ក្នុងទស្សនកិច្ចនេះ គ្រូអាចពន្យល់អំពីជ្រុងផ្សេង ៗ ក្នុងថ្នាក់រៀន សកម្មភាពរបស់សិស្ស និង បង្ហាញស្នាដៃរបស់សិស្ស ។ មាតាបិតា មានឱកាសសួរសំណួរដល់គ្រូ និង គ្រូគួរតែព្យាយាមនិយាយអំពីការរីកចំរើនរបស់សិស្ស ។

<u>គ្រូចុះទៅជួបមាតាបិតាសិស្សនៅផ្ទះ</u> : គ្រូគួរតែជួបជាមួយមាតាបិតារបស់សិស្ស ដែលប្រឈមមុខទៅនឹងបញ្ហា ដូចជា ការត្រួតថ្នាក់ ឬ ការបោះបង់ចោលសាលារៀន ។ គ្រូព្យាយាមវិភាគមូលហេតុសម្រាប់បញ្ហានេះ ។ គ្រូគួរតែពន្យល់អំពីសារៈសំខាន់នៃការរៀនសូត្រ និង ផ្តល់ព័ត៌មានដល់មាតាបិតា អំពីសកម្មភាពថ្នាក់កែតម្រូវ , សកម្មភាពអាហារូបករណ៍ . . . ។ល ។

<u>សៀវភៅទំនាក់ទំនង</u> : គ្រូអាចធ្វើទំនាក់ទំនងជាមួយមាតាបិតាសិស្សស្តីអំពីបញ្ហាផ្សេង ៗ តាមរយៈសៀវភៅទំនាក់ទំនង ។

<u>សៀវភៅតាមដាន</u> : គ្រូអាចធ្វើទំនាក់ទំនង តាមរយៈការប្រើប្រាស់សៀវភៅសម្រាប់សិស្សម្នាក់ ៗ ទាក់ទង

នឹងបញ្ហាការរៀនសូត្រ ។

❖ ក្រោយពីបានពិភាក្សាសកម្មភាពខាងលើនេះ អ្នកសម្របសម្រួល ជួយសិក្ខាកាមកំណត់សកម្មភាពណាខ្លះដែលគេចង់អនុវត្ត ដើម្បីពង្រឹងទំនាក់ទំនងរវាងមាតាបិតាសិស្ស និង គ្រូ ។ នាយកសាលា ត្រូវតែធានានូវការកំណត់កាលបរិច្ឆេទដើម្បីអនុវត្តសកម្មភាពនីមួយ ៗ ។

## 2. ការរៀបចំក្តារខៀនផ្សព្វផ្សាយព័ត៌មានតាមភូមិស្តីអំពីសកម្មភាពសាលារៀន :

❖ អ្នកសម្របសម្រួល ពន្យល់អំពីការដាក់ក្តារខៀនផ្សាយព័ត៌មានតាមភូមិ ឬ តាមទីមានមនុស្សច្រើន ។ ក្តារខៀននេះអាចផ្តល់ព័ត៌មានស្តីអំពីសកម្មភាពសាលារៀនសម្រាប់សហគមន៍ និង គ្រូ ស្តីអំពីសំណួរដូចខាងក្រោមនេះ ÷

ក/ តើគួរតែដាក់ក្តារខៀននេះនៅទីណា ?

- គួរតែពិចារណាលើចំណុចដូចតទៅ : ចំនួនមនុស្សដែលមកកន្លែងនេះយ៉ាងទៀងទាត់ ( ដូចជា ផ្សារ)
- ធាតុអាកាស ( ក្តារខៀនគួរតែមានដំបូល ) ។

ខ/ តើអ្នកណាទទួលខុសត្រូវសម្រាប់បិទព័ត៌មានថ្មី ៗ លើក្តារខៀនបានទៀងទាត់ ?

- សិស្សានុសិស្ស
- គ្រូ
- មាតាបិតាសិស្ស
- សមាគម សិស្ស ។

គ/ តើគួរតែផ្សព្វផ្សាយព័ត៌មានយ៉ាងណាខ្លះ ?

- គួរតែចំណាយពេលវេលាច្រើនក្នុងការពិចារណាលើសំណួរនេះ ។ ប្រសិនជាមិនមានព័ត៌មានថ្មីគួរអោយចាប់អារម្មណ៍ដើម្បីបិទលើក្តារខៀនបានទៀងទាត់ ប្រជាជននឹងលែងចាប់អារម្មណ៍នឹងក្តារខៀននេះ ។ មិនគួរប្រើប្រាស់ក្តារខៀនសម្រាប់បិទព័ត៌មានប្រភេទ ដូចជា សេចក្តីប្រកាសរបស់នាយកសាលាស្តីអំពីពេលវេលាប្រជុំ . . . ។ល ។ ព័ត៌មានបែបនេះមិនលើកទឹកចិត្តសិស្សក្នុងការរៀនសូត្រទេ ។ អ្នកសម្របសម្រួល គួរតែរំលឹកសិក្ខាកាមឡើងវិញថា សកម្មភាពនេះមានគោលបំណងលើកទឹកចិត្តសិស្សក្នុងការរៀនសូត្រ ។ អ្នកសម្របសម្រួលអោយសិក្ខាកាមពិចារណាអំពីទំនាក់ទំនងគ្រប់ក្តារខៀនផ្សាយព័ត៌មាន និង សកម្មភាពផ្សេង ៗ ដែលគេកំពុងអនុវត្តក្នុងកម្មវិធីសាលាកុមារមេត្រី ។ អ្នកសម្របសម្រួលអាចបង្ហាញគំនិតយោបល់ថ្មី ៗថែមទៀតលើបញ្ជីសេវាកម្មទោះបីជាសាលារៀនពុំទាន់មានបទពិសោធន៍អនុវត្តសកម្មភាពនេះ ។ ដូច្នេះអាចលើកសកម្មភាពដូចខាងក្រោមជាប្រភពព័ត៌មានសម្រាប់ក្តារខៀនផ្សព្វផ្សាយព័ត៌មាន ÷

- រូបថតថ្នាក់កុមារមេត្រី
- ទស្សនាវដ្ដីរបស់ក្រសួងអប់រំយុវជននិងកីឡា ស្ដីអំពីសកម្មភាពគួរអោយចាប់អារម្មណ៍
- រូបថតសកម្មភាពបំណិនជីវិត
- រូបថតសកម្មភាពក្នុងបណ្ណាល័យ
- ព័ត៌មានអំពីសកម្មភាពថ្នាក់បំប៉នសិស្សបន្ថែម
- ស្នាដៃរបស់សិស្សមួយចំនួន
- ស្នាដៃសំណេរច្នៃប្រឌិតរបស់សិស្ស ឬ គ្រូ ឬ សហគមន៍
- លទ្ធផលនៃការសម្ភាសន៍ដែលសិស្សបានធ្វើជាមួយសមាជិកសហគមន៍
- លទ្ធផលនៃគំរោងស្រាវជ្រាវធ្វើដោយសិស្ស
- លទ្ធផលនៃការស្រាវជ្រាវអំពីប្រវត្តិសាស្ត្រមូលដ្ឋាន ធ្វើដោយសិស្ស
- សំបុត្រផ្ញើពីសិស្សនៃសាលាដទៃទៀត
- ការពិពណ៌នាអំពីសកម្មភាពផ្សារប្រឌិតសរសេរដោយសិស្ស
- ឈ្មោះសិស្សក្នុងសមាគម
- ផែនការរបស់សមាគមសិស្ស
- របាយការណ៍សរសេរដោយសមាគមសិស្ស
- លទ្ធផលនៃការស្រាវជ្រាវស្ដីអំពីបញ្ហាយេនឌ័រក្នុងការអប់រំ
- ព័ត៌មានអំពីសកម្មភាពសិស្សពិការ
- ព័ត៌មានអំពីសុខភាព សរសេរដោយសិស្ស
- ព័ត៌មានអំពីសកម្មភាពរៀនបន្ថែមនៅផ្ទះ ( ឧទាហរណ៍ : ផ្សព្វផ្សាយឈ្មោះក្រុមគ្រួសារដែលបានខិតខំប្រឹងប្រែងធ្វើសកម្មភាពនេះជាប្រចាំខែ ) ។